ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៣ លេខ ១៦ សប្តាហ៍ទី ៤ ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

មាតិកា

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១២៨ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក អរ ហ៊ុបគៀត (OR HUP KIAT) ជនជាតិសិង្ហបុរី សញ្ជាតិសិង្ហបុរី កើតនៅសាធារណរដ្ឋសិង្ហបុរី ដោយប្ដូរឈ្មោះជា អួន ហាតគេត (ORN HAT KIAT) ១៨០៣

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១២៩ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ឆិន អាយមីង (CHEN AIMING) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តជើជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយប្ដូរឈ្មោះជា ឈិន ម៉េង (CHEN MENG) ១៨០៤

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣០ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ម៉ៅ សៀងវ៉ាង (MAO XIANGWANG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តជីជាំង សាធារណរដ្ឋប្រជាមានិតចិន ១៨០៥

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក យ៉ាង ជួនឆាង (YANG CHUANQUAN) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តជ័ងឈីង សាធារណរដ្ឋប្រជាមានិតចិន ១៨០៦

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣២ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក រ៉ូប៊ឺតវីលសុន ហ្គែនណឺ (ROBERT WILSON GARNER) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតនៅទីក្រុងអូហ្គូស្តា រដ្ឋចចារ សហរដ្ឋអាមេរិក ១៨០៧

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍនី ចំពោះ ក្រុមហ៊ុន ចំនួន ១២ ក្រុមហ៊ុន និង សប្បុរសជន ជាតិ និង បរទេស ចំនួន ១១ រូប ១៨០៨

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣៤ ស្ដីពី ការដាក់ឱ្យចូលនិវត្តន៍ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៥០ រូប ១៨១០

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ លោកស្រី អស់លោកជាមន្ត្រីរាជការ និង សប្បុរសជន ចំនួន ៣៨ រូប ១៨១៣

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ម៉ា រ៉ូយីន (MA RUYIN) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តសានទុង សាធារណរដ្ឋប្រជាមានិតចិន ១៨១៤

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣៧ ស្តីពី ការតែងតាំងឯកឧត្តម គួច ចាន់នី ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ១៨១៥

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ មន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ចំនួន ០៥ រូប ១៨១៦

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៣៩ ស្តីពី ការតែងតាំងលោក ញ៉ុត អៀតខួន ជា ឧកញ៉ា ១៨១៧

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៤០ ស្តីពី ការតែងតាំងឯកឧត្តម ម៉ែន សារឿន ជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៨១៨

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៤២ ស្តីពី ការតែងតាំងលោក សួខ ពិសិដ្ឋ ជា ឧកញ៉ា ១៨១៩

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៤៣ ស្តីពី ការតែងតាំងលោកជំទាវ និន ស៊ូយៀត ជា ឧកញ៉ា ១៨២០

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៤៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម ឃឹម ម៉ុណ្ណ ១៨២១

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៤៥ ស្តីពី ការតែងតាំងលោក ចាន់ ស៊ូអៀង ជា ឧកញ៉ា ១៨២២

១១.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៤៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ៤០ រូប ១៨២៣

១២.០២.២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៤៨ ស្តីពី ការតែងតាំងឯកឧត្តម ឡឹម តេជពិសី ជាទីប្រឹក្សាអមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានឋានៈស្មើ អគ្គនាយក ១៨២៥

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១២.០២.២០១៣-អនុក្រឹត្យលេខ ៦០ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៨០១ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម ក្នុងនោះកាត់ចេញពីគម្រប់ព្រៃឈើ ឆ្នាំ ២០០២ និង កាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន សាមលីញ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥២៥ គ្រួសារ ១៨២៦

១២.០២.២០១៣-អនុក្រឹត្យលេខ ៦១ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ១.៨៩៣,៥ ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះកាត់ចេញពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារ៍ណ នីហារ៍ណ និង អភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និង កែច្នៃ) កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃ និង កាត់ចេញពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៧៥ គ្រួសារ នៅឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង ១៨២៩

១៣.០២.២០១៣-អនុក្រឹត្យលេខ ៦២ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៧១១,៣១ ហិកតា នៅស្រុកកែវសីមា ខេត្តមណ្ឌលគីរី ចេញពីដីតំបន់អភិរក្សជីវៈចំរុះសីមា និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិសមូហភាព ជូនសហគមន៍ជនជាតិភាគតិចពូង ចំនួន ៧២ គ្រួសារ និង ការផ្ដល់សិទ្ធិលើក្បាលដី ១៨៣២

១៥.០២.២០១៣-អនុក្រឹត្យលេខ ៦៣ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៧៤៨,៩៤ ហិកតា នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៨៣៥

១៥.០២.២០១៣-អនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៥.០៣០,៥១ ហិកតា នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងនោះកាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ឹមឌីអេសនីហារ៍ណ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៦៣ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៨៣៨

១៥.០២.២០១៣-អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៣.៣៨៩ ហិកតា នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ចេញពីដែនជម្រកសត្វព្រៃរនាមដូនសំ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៩៨ គ្រួសារ ១៨៤៣

០៤.១២.២០១២ -អនុក្រឹត្យលេខ **២៦៥១** ដល់អនុក្រឹត្យលេខ **២៦៨៧** អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ១៨៤៦

២.សេចក្ដីសម្រេច

១៤.០២.២០១៣ -សេចក្ដីសម្រេចលេខ ០៦ សសរ ស្ដីពី ការតែងតាំងសមាសភាពគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ១៨៨៣

៣.សារាចរណែនាំ

១២.០២.២០១៣ -សារាចរណែនាំលេខ ០១ សរណន ស្ដីពី ការរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៥ ឆ្នាំ ២០១៣ ១៨៨៦

III.ការងារបណ្ដាក្រសួង

១.លិខិតបទដ្ឋានគតិយុត្តក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៣.០១.២០១៣ -ប្រកាសលេខ ០៦៧ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូនីកតា ថេកណូឡូជី (ខេមបូឌា) បង្កើតរោងចក្រ ផលិតបង្គុំខ្សែតភ្ជាប់បរិក្ខាអេឡិកត្រូនិក ១៨៩០

២៣.០១.២០១៣ -ប្រកាសលេខ ០៦៨ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មៀវ អ៊ីភើរីល វើលដ៍ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៨៩៤

២៣.០១.២០១៣ -ប្រកាសលេខ ០៦៩ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តៃអ៊ីហ្ស៊ី អ៊ិនធើណេសិនណល បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៨៩៨

២.លិខិតបទដ្ឋានគតិយុត្តក្រសួងពាណិជ្ជកម្ម

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៥៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយអិលឌី អ៊ីមនិច** ១៩០២

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៦០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី.អាយ.ស៊ី.អេ (ខេមបូឌា) ខមភេនី លីមីធីត** ១៩០៤

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៦១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីអេ ដេវើឡុប អេនជីនារីង & ខនស្រ្តាក់សិន** ១៩០៦

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៦៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម្រែន អេសអេច (ខេមបូឌា)** ១៩០៨

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៦៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ាំបូ ខឹមម៉ិឌី (ខេមបូឌា) លីមីធីត** ១៩១០

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៦៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គិនេស ត្រាវ៉ែល (ខេមបូឌា)** ១៩១២

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៧១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សួខ ម៉ី ខេមបូ អ៊ិនធើណេសិនណល** ១៩១៤

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៧៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **សៀងហៃ អេឡិគទ្រិ ស៊ីធី អ៊ិនស្តូឡេសិន No.1 អេនជីនារីង ខបភើរេសិន** ១៩១៦

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៧៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផលិតគ្រឿងសង្ហារឹម ឈុន ហ្វា** ១៩១៧

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៧៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៉ង លី អ៊ិនវេសមេន អ៊ិនធើណេសិនណល (ខេមបូឌា)** ១៩១៩

p

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អរ ហ៊ុបគៀត** (OR HUP KIAT) ជនជាតិសិង្ហបុរី សញ្ជាតិសិង្ហបុរី កើតថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៥៧ នៅសាធារណរដ្ឋសិង្ហបុរី ដោយប្តូរឈ្មោះជា **អូន ហាតគៀត** (ORN HAT KIAT)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បរ.១៣០២.១២៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ ១៣៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
[illegible]

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឆិន អាយមីង** (CHEN AIMING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៦៩ នៅខេត្តជើជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ឈិន ម៉េង** (CHEN MENG)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធានា: ១៣០២.១៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ: ១៤១ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋាភិបាល

ស៊យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ម៉ៅ សៀងវុង** (MAO XIANGWANG) ជនជាតិចិន សញ្ញាតិចិន កើតថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦៩ នៅខេត្តចឺជាំង សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ១៤២ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ២០១៣
[illegible]រាជរដ្ឋាភិបាល
ស៊យ សុខា

៣៧៥.១៣០២.១៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ាង ជួនក្វាង** (YANG CHUANQUAN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៥៩ នៅខេត្តជឺងឈឹង សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចករ.១៣០២.១៣២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

លេខ: [illegible] ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៣២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **រ៉ូប៊ឺតវីលសុន ហ្គែណឺ** (ROBERT WILSON GARNER) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៧ នៅទីក្រុងអូហ្គូស្តា រដ្ឋចចារ សហរដ្ឋអាមេរិក។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារលេខ.១៣០២.១៣៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

លេខៈ១៣៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនជាតិ និងបរទេស ដែលបានលះបង់កំលាំងកាយ ចិត្ត ប្រាជ្ញា ពេលវេលា និងធនធានយ៉ាងច្រើន ដើម្បីបម្រើសកម្មភាពមនុស្សធម៌ របស់កាកបាទក្រហមកម្ពុជា ។

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ៖

១- **ក្រុមហ៊ុន** CHINA NATIONAL AERO-TECHNOLOGY IMPORT&EXPORT CORPORATION
២- Mr. YANG SHOPING **ក្រុមហ៊ុន** XING YUAN KANNG YEAK Co., LTD
៣- **ក្រុមហ៊ុន** CHINA ROAD & BRIDGE CORPORATION
៤- **ក្រុមហ៊ុន** XIAN AIRCRAFT INTERNATIONAL CORPORATION
៥- Mr. WU JINGWEI
៦- **ក្រុមហ៊ុន** CHINA HUADIAN HONG KONG COMPANY LIMIDED
៧- **ក្រុមហ៊ុន** SINOHYDRO CORPORATION LIMITED
៨- Mr. TOM KIM SON **ក្រុមហ៊ុន** DYNAMIC PHARMA
៩- Mr. CHAN HUY LUONG **ក្រុមហ៊ុន** DYNAMIC PHARMA
១០- **ក្រុមហ៊ុន ឈីង៉ើរ (ខេមបូឌា) លីមីធីត**
១១- **ក្រុមហ៊ុន** MISSIONPHARMA
១២- **ក្រុមហ៊ុន** GREATPHARMA
១៣- Mr. CHEN JIHONG
១៤- **លោក លឹម អ៊ួយ ក្រុមហ៊ុន ភាពីម៉ិច និង ក្រុមហ៊ុន អ៊ូជីសាន ដាំដើមឈើ នៅខេត្តពោធិ៍សាត់**
១៥- Mr. SUSUMU HAYASHI **តំណាងក្រុមហ៊ុន** SONATRA GROUP
១៦- **ឧកញ៉ា ជួង ឈឹម តំណាងសមាគមខ្មែរ-ចិន នៅកម្ពុជា**
១៧- **ក្រុមហ៊ុន** CHINA GUANGDONG FOREIGN CONSTRUCTION
១៨- **ក្រុមហ៊ុន** CAMBODIAN TATAY HYDROPOWER LIMITED

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

p

១៩- **ក្រុមហ៊ុន** BRITISH AMERICAN TOBACCO Co., LTD

២០- Mr. PATRICK TAN **ក្រុមហ៊ុន** MOET HENNESSY ASIA PACIFIC Pte., LTD

២១- **លោកជំទាវ ឡៅ ទិញ**

២២- Dr. LEE JOONG KEUN **ក្រុមហ៊ុន** BOOYONG KHMER Co., LTD

២៣- **ក្រុមហ៊ុន** SIHANOUKVILLE ECONOMIC ZONE Co., LTD

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៥៧.១៣០២.១៣៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ: ១៣៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣

អគ្គលេខាធិការ [illegible]

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សម្ពហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដាក់ឱ្យចូលនិវត្តន៍ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៖

ក-ថ្នាក់ឧត្តមសេនីយ៍ឯក :

១-ឧត្តមសេនីយ៍ឯក កៅ ទ្រី អត្តលេខ ០០០២៥៧
២-ឧត្តមសេនីយ៍ឯក ជុម ហាក់ អត្តលេខ ០០០២៧២
៣-ឧត្តមសេនីយ៍ឯក ទូ ស៊ុន អត្តលេខ ០០០០៨៦
៤-ឧត្តមសេនីយ៍ឯក ជុំ ឈាង អត្តលេខ ០០០០២៤

ខ-ថ្នាក់ឧត្តមសេនីយ៍ទោ :

១-ឧត្តមសេនីយ៍ទោ ឯក ធីរៈ អត្តលេខ ០០០៣៣៧
២-ឧត្តមសេនីយ៍ទោ ព្រហ្ម សារឿន អត្តលេខ ០០០៨២៣
៣-ឧត្តមសេនីយ៍ទោ សោម សុវណ្ណ អត្តលេខ ០០១៩៥៩
៤-ឧត្តមសេនីយ៍ទោ ម៉ូ គឹមថេង អត្តលេខ ០០២៧៣១
៥-ឧត្តមសេនីយ៍ទោ ព្រំ សារ៉េត អត្តលេខ ០០០២៣៤
៦-ឧត្តមសេនីយ៍ទោ សួន សារិន អត្តលេខ ០០០២៣៦

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

p

៧-ឧត្តមសេនីយ៍ទោ	ឆ្លាក់	ឈន់	អត្តលេខ ០០០៦២៩
៨-ឧត្តមសេនីយ៍ទោ	ឡូន	សំ	អត្តលេខ ០០៣២៧៨
៩-ឧត្តមសេនីយ៍ទោ	យូន	សាម៉ុន	អត្តលេខ ០០១២៣៨
១០-ឧត្តមសេនីយ៍ទោ	អ៊ិន	ហឿន	អត្តលេខ ០០៤៣៥២
១១-ឧត្តមសេនីយ៍ទោ	ប្រាក់	សយ	អត្តលេខ ០០០៦៤៨

គ-ថ្នាក់ឧត្តមសេនីយ៍ត្រី :

១-ឧត្តមសេនីយ៍ត្រី	ដួង	ចិត្រា	អត្តលេខ ០០០២៤៧
២-ឧត្តមសេនីយ៍ត្រី	តៀក	ផៃ	អត្តលេខ ០០០៤៨០
៣-ឧត្តមសេនីយ៍ត្រី	សេក	សេង	អត្តលេខ ០០១៤៤១
៤-ឧត្តមសេនីយ៍ត្រី	ឈាង	គន្ធី	អត្តលេខ ០០៣២៧៤
៥-ឧត្តមសេនីយ៍ត្រី	អៀង	អឿន	អត្តលេខ ០០០៦២២
៦-ឧត្តមសេនីយ៍ត្រី	ចែម	គុណសារោ	អត្តលេខ ០០០៦២៦
៧-ឧត្តមសេនីយ៍ត្រី	ម៉ែន	សារឿន	អត្តលេខ ០០៣២១៤
៨-ឧត្តមសេនីយ៍ត្រី	លី	លី	អត្តលេខ ០០៩០៥១
៩-ឧត្តមសេនីយ៍ត្រី	ចាន់	ខេមរៈ	អត្តលេខ ០០០៤៨៧
១០-ឧត្តមសេនីយ៍ត្រី	យឹម	ផាន់ណាត	អត្តលេខ ០០២១៧៦
១១-ឧត្តមសេនីយ៍ត្រី	ចាន់	ម៉ុនរោង	អត្តលេខ ០០៨៨២១
១២-ឧត្តមសេនីយ៍ត្រី	ចៅ	ឆន	អត្តលេខ ០០០៣៨០
១៣-ឧត្តមសេនីយ៍ត្រី	យិន	យាន	អត្តលេខ ០០០៣៩១
១៤-ឧត្តមសេនីយ៍ត្រី	គង់	សាវ៉ែន	អត្តលេខ ០០០៧២៦
១៥-ឧត្តមសេនីយ៍ត្រី	ស៊ាង	ចាន់	អត្តលេខ ០០០៩៥៤
១៦-ឧត្តមសេនីយ៍ត្រី	ខឹម	សុខេម	អត្តលេខ ០០១៦៣៧
១៧-ឧត្តមសេនីយ៍ត្រី	អ៊ុក	ណាង	អត្តលេខ ០០៣៩៣៩
១៨-ឧត្តមសេនីយ៍ត្រី	គង់	គូម៉ា	អត្តលេខ ០០២៤៦០
១៩-ឧត្តមសេនីយ៍ត្រី	ខៀម	តេង	អត្តលេខ ០០១៩៣២
២០-ឧត្តមសេនីយ៍ត្រី	ឡឿង	សម្បត្តិ	អត្តលេខ ០០៣២៦០
២១-ឧត្តមសេនីយ៍ត្រី	គីម	ចេន	អត្តលេខ ០០០៦៩៦
២២-ឧត្តមសេនីយ៍ត្រី	គាំង	ផេង	អត្តលេខ ០០៣២៧៣
២៣-ឧត្តមសេនីយ៍ត្រី	កែន	សុផាត	អត្តលេខ ០០២១១១
២៤-ឧត្តមសេនីយ៍ត្រី	យង់	សារិន	អត្តលេខ ០០១២៦១
២៥-ឧត្តមសេនីយ៍ត្រី	ឆា	គៀត	អត្តលេខ ០០២៥៣៦
២៦-ឧត្តមសេនីយ៍ត្រី	សម	សារិទ្ធ	អត្តលេខ ០០២៥៥១
២៧-ឧត្តមសេនីយ៍ត្រី	ហេង	ស្រួយ	អត្តលេខ ០០២៥៧៧
២៨-ឧត្តមសេនីយ៍ត្រី	ទូ	ហ៊ាន់ថា	អត្តលេខ ០០០៧៣៨
២៩-ឧត្តមសេនីយ៍ត្រី	កែម	ផាត	អត្តលេខ ០០០៧៨០
៣០-ឧត្តមសេនីយ៍ត្រី	អឹល	សំផន	អត្តលេខ ០០២៤១៧
៣១-ឧត្តមសេនីយ៍ត្រី	ជ័យ	សែន	អត្តលេខ ០០០៥០៧
៣២-ឧត្តមសេនីយ៍ត្រី	មាស	ច័ន្ទគីរី	អត្តលេខ ០០០៩៤៥

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣៣-ឧត្តមសេនីយ៍ត្រី **ព្រាប សារុន** អត្តលេខ ០០០៩៦០

៣៤-ឧត្តមសេនីយ៍ត្រី **យន់ ឡឿន** អត្តលេខ ០០១០៣៤

៣៥-ឧត្តមសេនីយ៍ត្រី **ឡុញ ជុស** អត្តលេខ ០០៣៨៩៩

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.០២១៣.១៣៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

លេខៈ ១៣៣ ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៣៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោកស្រី អស់លោកជាមន្ត្រីរាជការ និងសប្បុរសជន ចំនួន ៣៨ រូប បានខិតខំយកអស់កម្លាំងកាយ ចិត្ត បំពេញភារកិច្ចរបស់ខ្លួនរួមចំណែកក្នុងការអភិវឌ្ឍលើគ្រប់វិស័យក្នុងស្រុកបាណន់ ខេត្តបាត់ដំបង

នូវ

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១-លោក ស្រេង តេកអាន
២-លោក តាន់ ចាន់ធារិទ្ធ
៣-លោក ម៉ែ ឈីមសេង
៤-លោក សួន គន្ធី
៥-លោក សំ សោភា
៦-លោក យូ ឡុំចាន់សារ៉ា
៧-លោក មេ ម៉ិនណារី
៨-លោក ម៉ិន កុសល
៩-លោក ញ៉ុង សយសុធី
១០-លោក អឿន សារ៉ុន
១១-លោក សុខ គុណា
១២-លោក សាន ហ៊ិន
១៣-លោក យ៉ឹន ចាសនា
១៤-លោក រឹម សារដ្ឋ
១៥-លោក អែល អាន
១៦-លោក ហាង សារិន
១៧-លោកស្រី គី យក់មិន
១៨-លោក សួស សុផាត
១៩-លោក យ៉ឹម និព្វមុនី
២០-លោក ចែត្រា សិថា
២១-លោកស្រី សៀងឯម មករេត

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោក ឈានតៀន
២-លោក ជុំ ញ៉ី
៣-លោក អ៊ុង ប៊ុនជ័យ
៤-លោក អ៊ុច រ៉ា
៥-លោក ចាន់ ទាន់នី
៦-លោក សយ តារាវិចិត្រ
៧-លោក ហាត ខ្មៅឡៃ
៨-លោក កើស ចិន្ដា
៩-លោក គីម ស៊ុនរិទ្ធ
១០-លោក ខិន ចន្ទ្រះ
១១-លោក ចាន់ សំបូរ
១២-លោក គីម ណារ៉ា
១៣-លោក គិត សុចន្តី
១៤-លោក ជាល សុផល
១៥-លោក សំបូរ ផូ
១៦-លោក អ៊ាន មាឃ
១៧-លោក ហ៊ុំ ជាទី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានឃើញ១៣០២.១៣

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ... ឆ្នាំ២០១៣
អគ្គ... បាល
សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ម៉ា រូយីន** (MA RUYIN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៦៧ នៅខេត្តសានទុង សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ. ១៧០២-១៧៧

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

លេខ: ១៤០ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ហូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បាន ទ្រង់យល់ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បាន ទ្រង់យល់ ព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឡូច ចាន់នី** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ១៣០ ប.ល
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការ[illegible]រដ្ឋាភិបាល
សយ សុខា

៣៣៧. ១៣០២.១៣៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៣៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ចំនួន០៥រូប ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចជូនក្រសួង កន្លងមក

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-ឯកឧត្តម សុខ គុន
២-លោក ប៉ែន ចំនួសុខរិន
៣-លោក ង៉ូម បូរ៉ែណា
៤-លោក សោម សាធាន
៥-លោក ហែម ហ៊ឹម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានឃើញ.១៣០២.១៣៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១៣

លេខៈ ១៣២ ប.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល

ជ័យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោក ញ៉ឹក អៀកធួន

ជា

ឧកញ៉ា

ព្រះមហាក្សត្រលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចារស. ១៧០២.១៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ: ១៣៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣

អគ្គលេខាធិការនៃទីស្តីការរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ម៉ែន សារឿន** ជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

តរល.១៣០២.១៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

លេខ: ១២៥ ច.ល
បានឃើញចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល
សុខា

p

ព្រះរាជក្រឹត្យ

៖ស/រកត/០២១៣/១៤៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោក សួន ពិសិដ្ឋ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លាស. ១៣០២. ១៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខៈ ១៤៤ ច.ល
[illegible]ចម្លងចែក
[illegible] ថ្ងៃទី[illegible] ខែ កុម្ភៈ ឆ្នាំ២០១៣
[illegible]រាជរដ្ឋាភិបាល
[illegible]យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោកជំទាវ និន ស៊ូយៀក

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការ. ១៣០២.១៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ: ១៤៥ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរង [illegible] រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម ឃឹម ប៊ុណ្ណ

ដែលបានខិតខំបំពេញភារកិច្ចជូនជាតិមាតុភូមិ និងមានស្នាដៃល្អ
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១៣០២.១៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខៈ ១៤៨ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ កុម្ភៈ ឆ្នាំ២០១៣
[illegible]រដ្ឋាភិបាល

ស៊យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

គ្រាស់បង្គាប់

តែងតាំង :

លោក ខ៉ាន់ ស៊ួអៀង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible] ១៣០២.១៤២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

លេខ: ១៤៧ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៨៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ៤០ រូប ដែលមានគុណបំណាច់
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោកជំទាវ ឃ្វី ស៊ៀង ចិញ្ចហ៊ួរ ៣- លោក ឈិន ខេមរា

២- លោក ប៊ិច សម្បត្តិ ៤- លោក គូល គីឡាធីរៈ

ខ/គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិមុនីវង្ស គុសុមៈនារីរត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោកជំទាវឧកញ៉ា អៀប ណៃ

គ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-លោក សួន សុខ ២-លោក សៅ សេងហាត់

ឃ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោកជំទាវ ឈឹម សុភ័ណ្ឌ ៧-លោក តាត់ ប៊ុនហ៊ាំង

២-លោក ញាណ សុមុន្នី ៨-លោក អោម សារ៉ាត់

៣-លោក ប៊ុន គុយ ៩-លោក គង់ ចាន់ថន

៤-លោក គឹម សុមេធ ១០-លោក សោម សត្ថាមុនី

៥-លោក ឡុង សុគន្ធា ១១-លោក ម៉ី សុភាព

៦-លោក ស៊ៀក ដារ៉ា

ROYAUME DU CAMBODGE

ង/គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

១-ឯកឧត្តម **ឆាង យូនម៉ឹង**

២-លោក **កែម ខាសនា**

ច/គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១-លោកស្រី **គីម បូរ៉ាវី**

ឆ/គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** :

១-លោក **ឆាន់ ជីនហួ**

២-លោក **ឡុង ចិនអ៊ី**

៣-លោកស្រី **ចាង យ៉ាន**

៤-លោក **ចូ សាឡុង**

៥-លោក **យ៉ាន គីងលើង**

៦-លោក **ស្លុង រស់**

៧-លោក **ហ៊ុយ ជីចិត**

៨-លោក **ឆាង លីង**

៩-លោក **ឆាង ខាយស៊ុយ**

១០-លោក **ចិន សុផល**

១១-លោក **អ៊ុក សាផាន**

១២-លោក **ញ៉ាស់ ចិន្ត្រា**

១៣-លោក **អោម រី**

ជ/គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១-លោក **ឈឹម ចាន់ធី**

២-លោក **មឿន ចាន់ថូ**

៣-លោក **គីម ច័ន្ទរត្តនា**

៤-លោក **រិន្ទ រ៉ូលែន**

៥-លោក **កែម សារ៉ាត់**

៦-លោក **ជួង គន**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

[illegible].១៣០២.១៤៧

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ ១៤៩ ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣

អគ្គ[illegible]រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៤៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/៩៦៦ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឡឹម ពេជពិសី** ជាទីប្រឹក្សាអមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

០២១៣.១៣៧៤.១៤៨

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៣

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៦២ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីសរុបទំហំ ៨០១ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម ក្នុងនោះ កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និងកាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន សាម លីញ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥២៥ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

p

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញស្មារតីលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៨៤ លគកច ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ដីសរុបទំហំ ៨០១ ហិកតា ក្នុងនោះ ទំហំ ៥៧០ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងទំហំ ២៣១ ហិកតា កាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន សាមលីញ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិខ្លាយ ឃុំតំបែរ ស្រុកតំបែរ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥២៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិខ្លាយ ឃុំតំបែរ ស្រុកតំបែរ ។

មាត្រា ៣ ..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

p

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦២.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកាត់ដីសរុបទំហំ ១.៨៩៣,៥ ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារណ៍នីហារណ៍ និង អតិថឡន់ដំណាំកសិ-ឧស្សាហកម្ម និងកែច្នៃ) កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងកាត់ចេញពីព្រៃសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៧៥ គ្រួសារ នៅឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៦៣ ខបប ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ដីសរុបទំហំ ១.៨៩៣,៥ ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះ ទំហំ ១.៤៨៦ ហិកតា កាត់ចេញពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារណ៍នីហារណ៍ និងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និងកែច្នៃ) ទំហំ ៤៦ ហិកតា កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងទំហំ ៣៦១,៥ ហិកតា កាត់ចេញពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងភូមិ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំសរុប ១.១៤៩ ហិកតា ក្នុងនោះ (១) ទំហំ ១.១០១ ហិកតា កាត់ចេញពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារណ៍នីហារណ៍ និងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និងកែច្នៃ) (២) ទំហំ ៤៦ ហិកតា កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និង(៣)ទំហំ ០២ ហិកតា កាត់ចេញពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិកំប្រង់
- ផ្ទៃដីទំហំសរុប ៧៤៤.៥ ហិកតា ក្នុងនោះ (១) ទំហំ ៣៨៥ ហិកតា កាត់ចេញពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារណ៍នីហារណ៍ និងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និងកែច្នៃ) និង(២) ទំហំ ៣៥៩,៥ ហិកតា កាត់ចេញពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិទួលទិល

p

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៧៥ គ្រួសារ នៅឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងភូមិ ដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៥៤ គ្រួសារ នៅភូមិកំប្រង់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២១ គ្រួសារ នៅភូមិទួលទិល ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៦៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៧១១,៣១ ហិកតា នៅស្រុកកែវសីមា ខេត្តមណ្ឌលគិរី ចេញពីដីតំបន់អភិរក្សដីខៈចំរុះសីមា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិភាគតិចពូន ចំនួន ៧២ គ្រួសារ និងការផ្តល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
